# OCRA

ការិយាល័យតស៊ូមតិ សំរាប់សិទ្ធិរបស់អតិថិជន (OCRA, Office of Clients’ Rights Advocacy ) គឺជាការិយាល័យ មួយមានទូទាំង រដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ Disability Rights California ដែលកាលមុនគឺជាក្រុមហ៊ុន មានឈ្មោះថា Protection & Advocacy, Inc., តាមរយ: កិច្ចព្រមព្រៀងជាមួយ California Department of Developmental Services ។OCRA អនុវត្តនូវ ការតស៊ូមតិ លើសិទ្ធិរបស់អតិថិជន (CRA, Clients’ Rights Advocate) នៅតាមមណ្ឌល ប្រចាំតំបន់នីមួយៗ ។CRA គឺជាមនុស្សដែល បានទទួលការ បណ្តុះបណ្តាល ឱ្យចេះជួយការពារ សិទ្ធិរបស់ពលរដ្ឋ ដែលមានពិការភាព ។

## នរណាអាចបានទទួលសេវាកម្ម តស៊ូមតិសិទ្ធិអតិថិជន?

ពលរដ្ឋគ្រប់រូបដែលស្ថិតក្នុងភាពទន់ខ្សោយ សមាជិក គ្រួសាររបស់គេ ឬពលរដ្ឋគ្រប់រូប ដែលមានការ ចាប់អារម្មណ៏ អាចសួរមកកាន់ CRA អំពីសិទ្ធិរបស់ បុគ្គលលើការការពារសំរាប់ភាពទន់ខ្សោយ ។ CRA នឹងឆ្លើយនូវសំណួររបស់អ្នក ឬបញ្ជូនអ្នកទៅកាន់អ្នក ផ្សេងទៀតដែលអាចជួយអ្នកបានប្រសើរជាងនេះ ។

## សិទ្ធិអតិថិជនក្នុងការតស៊ូមតិ :

- អាចពិគ្រោះយោបល់ជាមួយ និងអាចជួយពលរដ្ឋ ដែលត្រូវការការពារសំរាប់ភាពទន់ខ្សោយនិង គ្រួសាររបស់គេ ឱ្យបានទទួលសេវាជ្រោមជ្រែង ។
- អាចធ្វើជាអ្នកតំណាងឱ្យពលរដ្ឋដែលត្រូវការការ ពារសំរាប់ភាពទន់ខ្សោយ ដោយផ្ទាល់នៅក្នុង សវនាការរដ្ឋបាល ។
- អាចផ្តល់ការបណ្តុះបណ្តាលអំពីសិទ្ធិ ដល់អតិថិជន គ្រួសាររបស់គេ មណ្ឌលផ្តល់សេវាប្រចាំតំបន់ និងក្រុមសហគមន៏ដែលមានការចាប់អារម្មណ៏ ។
- អាចស៊ើបអង្កេតលើបណ្តឹងតវ៉ា អំពីការបដិសេធ លើសិទ្ធិណាមួយ ដែលអតិថិជនត្រូវបានទទួល ប្រសិនបើពាក្យបណ្តឹងតវ៉ានោះ ពាក់ព័ន្ធនឹង អង្គការ ។
- អាចជួយធានាលើការអនុវត្តន៏តាមច្បាប់ ពាក់ព័ន្ធនឹង សិទ្ធិដែលអង្គការបដិសេធ ។

*អ្នកអាចដាក់ពាក្យបណ្តឹងសារទុក្ខ ប្រសិនបើអ្នកមិន ពេញចិត្តជាមួយនឹងសេវា ដែលផ្តល់ឱ្យអ្នកដោយ OCRA ។*

## តើសេវាកម្ម/ភ្នាក់ងារផ្តល់សេវាកម្ម របស់ CRA អាចជួយអ្វីបានខ្លះ?

សាលារៀន

សុវត្ថិភាពសង្គម

Medi-Cal

ការត្រូវគេព្រងើយកន្តើយដាក់

នីតិសម្បទាសុខភាពផ្លូវចិត្ត

ការរើសអើង

មជ្ឈមណ្ឌលប្រចាំតំបន់

សេវាកម្មប្រចាំគ្រួសារ

ការធានារ៉ាប់រងឯកជន

អាណាព្យាបាល

ការប្រព្រឹត្តិរំលោភ

ការមើលថែរក្សាពេលថ្ងៃ

រឿងរ៉ាវឧក្រិដ្ឋ

ស្វ័យភាពផ្ទាល់ខ្លួន

ភាពអភិរក្ស និង

វិធីផ្សេងៗ

ផ្នែកផ្សេងទៀតនៃច្បាប់

## តើ CRA សំរេចចិត្តយ៉ាងដូចម្តេចក្នុងការធ្វើជា អ្នកតំណាងរបស់ខ្ញុំ ដោយផ្ទាល់?

ក្នុងការសំរេចចិត្ត ធ្វើជាអ្នកតំណាងរូបអ្នក ដោយផ្ទាល់ OCRA នឹងពិចារណា លើចំណុចដូចតទៅ :

- ភាពសមនឹងបានទទួល ចំពោះបណ្តឹងរបស់អ្នក
- សមត្ថភាពក្នុងការតស៊ូមតិរបស់អ្នក
- ធនធានដែល OCRA មាន
- ធនធានតស៊ូមតិផ្សេងទៀត ដែលអ្នកអាចប្រើបាន

## ហើយតើសិទ្ធិតស៊ូមតិអតិថិជន របស់អ្នក ជួយអ្វីបានខ្លះដល់រូបអ្នក?

**www.disabilityrightsca.org**

**ឈ្មោះ CRA និងលេខទូរស័ព្ទរបស់អ្នកគឺ ៈ**

**ឬអ្នកអាចទូរស័ព្ទហៅមកកាន់លេខ ៈ**

**1-800-390-7032**
**916-575-1615 សម្លេង**
**877-669-6023 សំរាប់អ្នកពិបាកស្តាប់**
**916-575-1623 ទូរសារ**

*រូបភាពលំអទំព័រមុខ គឺជាគំនូររបស់វិចិត្រករ Bob Sulin ។ លោក Sulin ជាពលរដ្ឋនៅស្រុក Sacramento គំនូររបស់គាត់បានដាក់បង្ហាញលើការតាំងពិពណ៌នៅទូទាំងរដ្ឋកាលីហ្វូនីញ៉ា ។ ភាគច្រើនគាត់គូរគំនូរដោយប្រើថ្នាំលាបគូរលើព័រស៊ីឡែន និងការឆ្លាក់អក្សរ ហើយគាត់មានភាពល្បីល្បាញចំពោះរូបតុក្កតាកំប្លែងស្លូត និងរូបតុក្កតាវិះគន់រឿងនយោបាយ ។ លោក Sulin គឺជាសិស្សនៅឯមណ្ឌលមណ្ឌលអតិថិជន Short Center North និងមណ្ឌលមណ្ឌលអតិថិជនប្រចាំតំបន់ Alta California ។*

ការបោះពុម្ពផ្សាយលេខ 5015.01
កែសំរួលឡើងវិញនៅខែតុលា ឆ្នាំ 2008

## តើអ្វីជាការិយាល័យការតស៊ូមតិសិទ្ធិរបស់អតិថិជន?

